រៀបរៀងដោយ វេជ្ជ.ហោង ណៃឃីម / វេជ្ជ.ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥

# វ៉ាក់សាំងបង្ការជំងឺ កញ្ជ្រឹល-ស្អូច-ស្រឡទែន (MMR Vaccine)

## ១- ហេតុអ្វីអ្នកត្រូវទទួលវ៉ាក់សាំងប្រភេទនេះ?

ជំងឺកញ្ជ្រឹល-ស្អូច-ស្រឡទែន ជាជំងឺដ៏ធ្ងន់ធ្ងរដែលគេជួបប្រទះជាញឹកញាប់ ជាពិសេសលើកុមារតូចៗ។

- **កញ្ជ្រឹល**
  - * វីរុសកញ្ជ្រឹលបង្កអោយមានជាសញ្ញាកន្ទួលក្រហមលើស្បែក ក្អក ហៀរសំបោរ រមាស់ភ្នែក និងគ្រុនក្តៅ។
  - * វាអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរដូចជា ការបង្ករោគក្នុងត្រចៀក រលាកសួត ប្រកាច់ ការប៉ះពាល់ខួរក្បាល និងអាចបណ្តាលអោយស្លាប់បាត់បង់ជីវិតទៀតផង។
- **ស្អូច**
  - * វីរុសស្អូចអាចបង្កអោយមានជាសញ្ញាកន្ទួលក្រហមលើស្បែក រលាកសន្លាក់ និងគ្រុនក្តៅ។
  - * ប្រសិនបើជំងឺស្អូចនេះកើតមានចំពោះស្ត្រីមានផ្ទៃពោះ វាអាចបណ្តាលអោយមានផលវិបាកយ៉ាងធ្ងន់ធ្ងរដូចជា រលូតកូន រឺកូនកើតមកអាចមានភាពមិនប្រក្រតីពីកំណើតធ្ងន់ធ្ងរ។
- **ស្រឡទែន**
  - * វីរុសស្រឡទែនបង្កអោយមានជាសញ្ញាគ្រុនក្តៅ ឈឺក្បាល ឈឺសាច់ដុំ លែងឃ្លានអាហារ និងហើមក្រពេញទឹកមាត់។
  - * វាអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរដូចជា ថ្លង់ រលាកស្រោមខួរ ការហើម និងមានការឈឺចាប់យ៉ាងខ្លាំងនៅនឹងពងស្វាស ឬអូវែ និងដោយកំរ វាអាចបណ្តាលអោយអា មិនអាចមានកូនបាន។

## ២- តើអ្នកណាខ្លះគួរទទួលវ៉ាក់សាំងបង្ការជំងឺនេះ? ហើយគួរធ្វើនៅពេលណា?

**កុមារ** ត្រូវទទួលវ៉ាក់សាំងនេះ ចំនួន២ដង៖

- ដូសទី១: នៅពេលដែលកុមារមានអាយុ៩ខែ
- ដូសទី២: នៅពេលដែលកុមារមានអាយុ៤-៦ឆ្នាំ

**មនុស្សពេញវ័យ** ដែលពុំធ្លាប់ទទួលវ៉ាក់សាំងនេះ ហើយពុំទាន់ដែលកើតជំងឺទាំងនេះ ត្រូវចាក់វ៉ាក់សាំងបង្ការនេះចំនួន២ដូស៖

- ដូសទី១: ត្រូវផ្តល់ឲ្យភ្លាមៗ
- ដូសទី២: នៅ ២៨ថ្ងៃ យ៉ាងតិច ក្រោយពីដូសទី១

## ៣- តើមនុស្សណាខ្លះដែលមិនគួរចាក់វ៉ាក់សាំងនេះ?

- អ្នកដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតដែលមាន ក្នុងវ៉ាក់សាំងនេះ
- អ្នកដែលមានប្រវត្តិប្រតិកម្មជាមួយថ្នាំ *NEOMYSINE*
- ស្ត្រីដែលកំពុងមានផ្ទៃពោះ

  *** ត្រូវចៀសវាងកុំអោយមានផ្ទៃពោះ រយៈពេល៤សប្តាហ៍ បន្ទាប់ពីចាក់វ៉ាក់សាំងនេះរួច**
- អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ
- អ្នកដែលកំពុងមានជំងឺ
- អ្នកដែលមានចំនួនផ្លាកែតចុះទាប
- អ្នកដែលធ្លាប់បានចាក់វ៉ាក់សាំងបង្ការជាទំរង់រស់ ក្នុងកំឡុងពេល ៤សប្តាហ៍ កន្លងមក
- អ្នកដែលបានបញ្ចូលឈាម ក្នុងពេលថ្មីៗនេះ

## ៤- ផលវិបាកដែលអាចកើតមានក្រោយចាក់វ៉ាក់សាំង

ដូចឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាលែកស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលវ៉ាក់សាំងបង្ការនេះអាច បណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ មានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ឈឺ ឬ ហើមត្រង់កន្លែងចាក់
- គ្រុនក្តៅ ឡើងកន្ទួលក្រហមលើស្បែក
- ហើមកូនកណ្តុរនៅថ្ពាល់ ឬ នៅត្រង់ក
- ប្រតិកម្មធ្ងន់ធ្ងរ (កំរមានណាស់)

**ប្រសិនបើមានសញ្ញាប្រតិកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**

Institut Pasteur du Cambodge